**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ១៧៤៤ អក

ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩

សាលក្រមលេខ៖ ៦៦ (ណ)

ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពជំនុំជំរះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**មេធាវី**

មេធាវី [redacted] មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ម៉ាន់ ពេជ្រមុន្នី(អវត្តមាន)

មេធាវី [redacted] មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]ឈិត(មានវត្តមាន)

**ដើម្បីជំនុំជំរះ** សំណុំរឿងព្រហ្មទណ្ឌលេខ: ១៧៤៤ អក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted] ឈិត ភេទប្រុស អាយុ ៦២ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] បាក់ស្រ៊ុន (ស្លាប់) ម្តាយឈ្មោះ[redacted]អ៊ាវទៀង (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ដារី មានកូន ០៦នាក់ ជានីតិជន ទោសពីមុន៖ គ្មាន។ (ក្រៅឃុំ)។

ត្រូវជាប់ចោទពីបទ៖ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ តាមបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ពេជ្រមុន្នី ភេទស្រី អាយុ ៤៩ឆ្នាំ មុខរបរ មេផ្ទះ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ B៣៦ ភូមិជ្រៃកោង សង្កាត់ចោមចៅ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឈុន(ស្លាប់) ម្តាយឈ្មោះ[redacted]គឹមចេង (ស្លាប់) ប្តីឈ្មោះ [redacted]ដ្ឋា មានកូន ០៥នាក់។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ១៥៥ ដកសព ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

បានឃើញ ដីកាដំណោះស្រាយលេខៈ ៣៨៣ ដកដស ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ៥៣២ ដកចត ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## អង្គហេតុរបស់ជនជាប់ចោទ

កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ ឈ្មោះ [redacted]ពជ្រមុន្នី បានទិញដីមួយកន្លែងទំហំ ៦០០ ម៉ែត្រការ៉េពីឈ្មោះ [redacted]ឃិត ស្ថិតនៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ដោយបានធ្វើកិច្ចសន្យាលក់ផ្តាច់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦។ នៅអំឡុងឆ្នាំ២០១៩ ឈ្មោះ [redacted]ពេជ្រមុន្នី បានស្នើសុំទៅសុរិយោដីដើម្បីធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់ ក្រោយពេលដែលមន្ត្រីជំនាញសុរិយោដីចុះវាស់វែងទើបដឹងដីដែលឈ្មោះ [redacted]ជ្រមុន្នី ទិញពីឈ្មោះ [redacted] ឃិត ខាងលើមានម្ចាស់កម្មសិទ្ធិហើយ ដែលមានឈ្មោះ [redacted] សុតិពល់ និងប្រពន្ធឈ្មោះ [redacted]ណារី។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់របាយការណ៍របស់មន្ត្រីយុត្តិធម៌

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្តាល
## យល់ឃើញថា

### ក.អំពីពិរុទ្ធជនៈ

១-តាមដីកាដំណោះស្រាយលេខៈ ៣៨៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted]ឃិត ភេទប្រុស អាយុ ៦២ឆ្នាំ មកតុលាការដើម្បីជំនុំជម្រះពីបទៈ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ តាមបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ឃិត បានឆ្លើយថាៈ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ ឈ្មោះ [redacted] ពេជ្រមុន្នី បានទិញដីពីខ្លួនក្នុងទំហំ ៦០០ម៉ែត្រការេ ដែលមានទីតាំងនៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ដោយបានធ្វើលិខិតលក់-ទិញដី ផ្ទេរកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ ដោយមានអាជ្ញាធរមូលដ្ឋាន ចុះហត្ថលេខាត្រឹមត្រូវតាមច្បាប់។ ក្រោយពីការប្រគល់ដីឱ្យទៅឈ្មោះ[redacted]ពេជ្រមុន្នី រួចមក ឈ្មោះនេះ បានត្រឡប់ទៅទីលំនៅគាត់នៅឯភូមិក្រពាំង ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង មិនមែនមកនៅលើដីនោះទេ លុះមកដល់កំឡុងឆ្នាំ២០១៩ ទើបគាត់ធ្វើប័ណ្ណកម្មសិទ្ធិលើដីនោះដោយមានអ្នកជំនាញមន្ទីរ សុរិយោដីខេត្តកណ្តាល ចុះទៅវាស់វែង តែពេលនោះគាត់មិនបានចំណាំដីដែលគាត់ទិញពីខ្លួននោះទេ ទៅវាស់វែងទៅលើដីរបស់ឈ្មោះ [redacted] សតិពល់ និងប្រពន្ធឈ្មោះ [redacted]ណារី ទេវិញ ទើបមន្ទីរសុរិយោដីខេត្តកណ្តាល បានប្រាប់ទៅគាត់ថា ដីនេះជាកម្មសិទ្ធិរបស់ឈ្មោះ [redacted]តិពល់ និងប្រពន្ធឈ្មោះ [redacted]ណារី ទើបគាត់ឡាំប៉ាប្តឹងចោទខ្លួនពីបទៈ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ។ ក្រោយមកគាត់បានរកដីនោះឃើញវិញ ហើយគាត់ហៅអ្នកសុរិយោដីខេត្តកណ្តាល ចុះទៅវាស់វែង និងធ្វើប័ណ្ណកម្មសិទ្ធិត្រឹមត្រូវឱ្យគាត់ម្តងទៀតរួចហើយ ក្នុងកំឡុងឆ្នាំ២០២១ លុះដល់ឆ្នាំ២០២២ ទើបមន្ទីរសុរិយោដីខេត្តកណ្តាលចេញវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ០៨១១១០០៥.២៦៣៥ ចុះថ្ងៃទី០៧ ខែកុម្ភៈ



Scanned with CamScanner

ឆ្នាំ២០២២ ដែលមានកម្មសិទ្ធិករឈ្មោះ [redacted] ពេជ្រមុន្នី និងឈ្មោះ [redacted] លីណា របស់មន្ទីរសុរិយោដីខេត្តកណ្តាល។ ក្រោយមកទើបគាត់ចូលមកបំភ្លឺចំពោះមុខតុលាការនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ សុំបញ្ចប់រឿងប្តឹងផ្តល់ពីរូបខ្លួន និងដកពាក្យបណ្តឹងនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២។

៣-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពេជ្រមុន្នី បានឆ្លើយថា៖ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០០៦ ខ្លួនបានទិញដីទំហំ ៦០០ម៉ែត្រការ៉េ ពីឈ្មោះ [redacted] ឈិត មានទីតាំងនៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ក្នុងតម្លៃ ៦៥,០០០(ប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិច ដោយខាងភូមិ ឃុំមានចេញលិខិតលក់ផ្តាច់ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦។ លុះដល់ឆ្នាំ២០១៩ ខ្លួនបានស្នើសុំទៅសុរិយោដី ដើម្បីធ្វើប្លង់កម្មសិទ្ធិ ប៉ុន្តែក្រោយពីមន្ត្រីជំនាញចុះវាស់វែងរួចហើយ ស្រាប់តែប្រាប់ខ្លួនថាដីខាងលើមានម្ចាស់កម្មសិទ្ធិរួចហើយគឺឈ្មោះ [redacted] សតិពល់ និងប្រពន្ធឈ្មោះ [redacted] ណារី ជាម្ចាស់កម្មសិទ្ធិ។ តែនៅពេលនេះខ្លួនឈប់ប្តឹងឈ្មោះ [redacted] ឈិត ទៀតហើយ ដោយមូលហេតុខ្លួនមិនចង់វែងឆ្ងាយ ព្រោះខ្លួនមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងនីតិវិធី ណាមួយឈ្មោះ [redacted] ឈិត មានវ័យចំណាស់ទៅហើយ។ ហើយខ្លួនក៏ទទួលបានប្តូររឹងពីដីដែលទិញពីឈ្មោះ [redacted] ឈិត នោះរួចហើយដែរ។

៤-តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌បានបញ្ជាក់ថា៖ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ នៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ពិតជាមានអង្គហេតុដែលឈ្មោះ [redacted] ពេជ្រមុន្នី បានទិញដីទំហំ ៦០០ម៉ែត្រការ៉េ ពីឈ្មោះ [redacted] ឈិត ដោយបានធ្វើកិច្ចសន្យាលក់ផ្តាច់ ។ នៅកំឡុងឆ្នាំ២០១៩ ឈ្មោះ ម៉ាន់ ពេជ្រមុន្នី បានស្នើសុំទៅខាងសុរិយោដីខេត្តកណ្តាល ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិ តែក្រោយពីការចុះវាស់វែងរួចពីខាងសុរិយោដីទើបដឹងថា ដីដែលទិញពីឈ្មោះ [redacted] ឈិត មានម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] សតិពល់ និងប្រពន្ធឈ្មោះ [redacted] ណារី ពិតមែន។

៥-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ឆ្លងតាមអង្គសវនាការនេះ តំណាងអយ្យការយល់ឃើញថា៖កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ នៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ពិតជាមានអង្គហេតុដែលឈ្មោះ [redacted] ពេជ្រមុន្នី បានទិញដីទំហំ ៦០០ម៉ែត្រការ៉េ ពីឈ្មោះ [redacted] ឈិត ដោយបានធ្វើកិច្ចសន្យាលក់ផ្តាច់ ។ នៅកំឡុងឆ្នាំ២០១៩ ឈ្មោះ [redacted] ពេជ្រមុន្នី បានស្នើសុំទៅខាងសុរិយោដីខេត្តកណ្តាល ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិ តែក្រោយពីការចុះវាស់វែងរួច ពីខាងសុរិយោដីទើបដឹងថា ដីដែលទិញពីឈ្មោះ [redacted] ឈិត មានម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] សតិពល់ និងប្រពន្ធឈ្មោះ [redacted] ណារី ពិតមែន។ ដូច្នេះតំណាងអយ្យការសូមដំកល់បទចោទនេះនៅដដែល តាមដីកាសន្និដ្ឋានស្ថាពរលេខ៖ ១៥៥ ដកសព ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ជាមូលដ្ឋាន។

៦-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ឈិត៖ឆ្លងកាត់តាមអង្គសវនាការ បានឱ្យដឹងថា កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ ពិតជាមានអង្គហេតុនៃការបង្កើតកិច្ចសន្យា លក់ទិញដីមួយកន្លែងរវាងកូនក្តីខ្ញុំឈ្មោះ [redacted] ឈិត និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពេជ្រមុន្នី ដោយបានធ្វើកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ ពិតប្រាកដមែន ដោយដីជាកម្មវត្ថុនៃកិច្ចសន្យាលក់ផ្តាច់ គឺពិតជាកម្មសិទ្ធិស្របច្បាប់របស់កូនក្តីខ្ញុំបាទមែន ម៉្យាងវិញទៀតគូភាគីបានបំពេញកាតព្វកិច្ចតាមកិច្ចលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាចប់សព្វគ្រប់ហើយ ដោយភាគីអ្នកលក់បានប្រគល់ដីទៅអ្នកទិញ ដើម្បីគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិ ហើយអ្នកទិញបានបង់ប្រាក់ថ្លៃដីគ្រប់ចំនួន។ បច្ចុប្បន្នដីនេះត្រូវបានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១១០០៥-២៦៣៥ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ ដោយមានឈ្មោះ [redacted] ពេជ្រមុន្នី និងឈ្មោះ [redacted] លីណា ជាម្ចាស់កម្មសិទ្ធិករស្របច្បាប់រួចរាល់ជាស្ថាពរហើយ។ ក្នុងនាមខ្ញុំជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ឈិត ស្នើសុំដល់លោកចៅក្រមមេត្តាឱ្យកូនក្តីរបស់ខ្ញុំបាទរួចផុតពីបទចោទប្រកាន់នេះផង។

៧-តាមចម្លើយរបស់ជនជាប់ចោទ ,ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបាយការណ៍របស់មន្ត្រីនគរបាល មានភាពស៊ីសង្វាក់គ្នា អាចបញ្ជាក់បានថា៖ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ នៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ពិតជាមានអង្គហេតុដែលឈ្មោះ [redacted] ពេជ្រមុន្នី បានទិញដីទំហំ ៦០០ម៉ែត្រការ៉េ ពីឈ្មោះ [redacted] ឈិត ដោយបានធ្វើកិច្ចសន្យាលក់ផ្តាច់ ពិតមែន តែក្នុងអំឡុងឆ្នាំ២០១៩ ឈ្មោះ [redacted] ពេជ្រមុន្នី បានស្នើសុំទៅខាងសុរិយោដីខេត្តកណ្តាល ដើម្បីធ្វើប័ណ្ណកម្មសិទ្ធិ តែក្រោយពីការចុះវាស់វែងរួច ពីខាងសុរិយោដីទើបដឹងថា ដីដែលទិញពីឈ្មោះ ជាម ឈិត មានម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] សតិពល់ និងប្រពន្ធឈ្មោះ [redacted] ណារី រួចក៏បានដាក់ពាក្យបណ្តឹងទៅលើឈ្មោះ [redacted] ឈិត។ ដោយហេតុថាដើមបណ្តឹងរដ្ឋប្បវេណីមានការយល់ភ័ណ្ឌច្រលំលើដីដែលឈ្មោះ [redacted] ឈិត បានលក់ឱ្យ រួចក៏បានរកដីរបស់ខ្លួនឃើញវិញ និងមានការដោះស្រាយបញ្ចប់រឿង ក៏បានដកពាក្យបណ្តឹងទៅលើឈ្មោះ [redacted] ឈិត រួចរាល់ហើយ។ ចំពោះរឿងហេតុដែលបានកើតឡើងនេះគឺផុតអាជ្ញាយុកាលហើយ ម៉្យាងវិញទៀត ការធ្វើកិច្ចសន្យាទិញលក់ដោយសារដើមបណ្តឹងរកដីមិនឃើញ ណាមួយរឿងនេះជារឿងរដ្ឋប្បវេណីសុទ្ធសាទ ហើយភាគីទាំងពីរក៏បានដោះស្រាយជាមួយគ្នារួចរាល់ហើយ។ បច្ចុប្បន្នដីនេះត្រូវបានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១១០០៥-២៦៣៥ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ ដោយមានឈ្មោះ [redacted] ពេជ្រមុន្នី និងឈ្មោះ [redacted] លីណា ជាម្ចាស់កម្មសិទ្ធិស្របច្បាប់រួចរាល់ជាស្ថាពរហើយ គប្បីតុលាការឱ្យឈ្មោះ [redacted] ឈិត ភេទប្រុស អាយុ ៦២ឆ្នាំ រួចផុតពីបទចោទប្រកាន់ពីបទ៖ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ។

៨-ពុំមានភស្តុតាង ដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើឈ្មោះ [redacted] ឈិត ភេទប្រុស អាយុ ៦២ឆ្នាំ (ក្រៅឃុំ) ពីបទ៖ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ តាមបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល នោះទេ។

**<u>ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាល វិនិច្ឆ័យសេចក្តី</u>**

១-ឱ្យជនជាប់ចោទឈ្មោះ [redacted] ឈិត ភេទប្រុស អាយុ ៦២ឆ្នាំ (មានសាវតាជាតិដូចខាងលើ) រួចផុតពីបទចោទប្រកាន់ពីបទ៖ លួចលក់អចលនវត្ថុរបស់អ្នកដទៃ ប្រព្រឹត្តនៅភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ តាមបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឈិត តែចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពេជ្រមុន្នី។

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជំរះ**
ហត្ថលេខ និងត្រា
[redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃ ព្រហស្បតិ៍ ១៣ កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
កណ្តាល,ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០២៣

បានឃើញ
**ចៅក្រម**
[redacted]

**ក្រឡាបញ្ជី**
[redacted]

ភារី

បានទទួលដំណឹង

ថ្ងៃ ព្រហស្បតិ៍ ១៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល,ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០២៣

**តំណាងអយ្យការ**

[redacted]